## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ១០០,១០០ ដុល្លារអាមេរិក
## សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពប្រាសាទនាគបួសក្នុងខេត្តព្រះវិហារ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១០០,១០០ ដុល្លារអាមេរិក ដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពប្រាសាទនាគបួស ខេត្តព្រះវិហារ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានិងលោក ចាប កុយ ប្រធានមន្ទីរ ធនធានទឹក និងឧតុនិយមខេត្តព្រះវិហារនៅស្ថានទូតជប៉ុន។

ជាមួយនឹងជំនួយនេះ មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារនឹងធ្វើការជួសជុលប្រព័ន្ធស្រោចស្រពប្រាសាទនាគបួស។ គម្រោងនេះរួមបញ្ចូលការជួសជុលទំនប់អាងទឹកប្រវែង៩០០ម៉ែត្រការជួសជុលប្រឡាយរងប្រវែង៨០០ម៉ែត្រនិងការសាងសង់សំណង់បញ្ចេញទឹក១កន្លែងសំណង់ស្ទាក់ទឹក១កន្លែង និងផ្លូវបង្ហៀរទឹក១។ យើងរំពឹងថា គម្រោងនេះនឹងជួយកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំ និងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ២៦៣គ្រួសារនៅក្នុងតំបន់។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ ប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។



កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាន

ផ្តល់ថវិកាជាង៤៨.៥លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៨៤គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*